ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**អគ្គលេខាធិការដ្ឋាន**
**ក្រុមលទ្ធកម្ម**
លេខ:...២/២៣......កសក.អល.កល

## សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃស្តីពីការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា ប្រចាំឆ្នាំ២០២៦ របស់អង្គភាពថវិកា អគ្គលេខាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អង្គភាពថវិកា អគ្គលេខាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា អគ្គលេខាធិការដ្ឋាន នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសទទួលអ្នកផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា ប្រចាំឆ្នាំ២០២៦ របស់អង្គភាពថវិកា អគ្គលេខាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

អង្គភាពថវិកា អគ្គលេខាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំឯកសារសម្រាប់ ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅក្រុមលទ្ធកម្ម នៃអង្គភាពថវិកា អគ្គលេខាធិការដ្ឋាន ដែលមានអាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី.....៤..... ខែ...មីនា.....ឆ្នាំ២០២៦ តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ០៦០ ២១ ២១ ៨៣)។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្ម នៃអង្គភាពថវិកា អគ្គលេខាធិការដ្ឋាន យ៉ាងយូរបំផុតត្រឹមថ្ងៃទី....៧......ខែ..មេសា...ឆ្នាំ២០២៦ វេលាម៉ោង...០៩:០០..................។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមអាសយដ្ឋាន ខាងលើ វេលាម៉ោង...០៩:០០..... ថ្ងៃទី....៧........ខែ..មេសា.... ឆ្នាំ២០២៦។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្ម នៃអង្គភាពថវិកា អគ្គលេខាធិការដ្ឋាន ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ..អង្គារ ១៥កើត..ខែ..ផល្គុន.....ឆ្នាំម្សាញ់ សប្តស័ក ព.ស២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី....៣.......ខែ..មីនា...... ឆ្នាំ២០២៦

**ប្រធានក្រុមលទ្ធកម្ម**
**អង្គភាពថវិកា អគ្គលេខាធិការដ្ឋាន**

**បណ្ឌិត សរ ចិត្រា**

**ចម្លងជូន:**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ កាលប្បវត្តិ